# មេរៀនទី ៥១: ព្រះបញ្ជូនគ្រោះកាចនៅស្រុកអេស៊ីព្ទ

## និក្ខមនំ ៧:៨ -១០:២៩

**គោលបំណង៖** គ្មានអ្វីដែលមានអំណាចជាងព្រះទេ។

**ខគម្ពីរចងចាំ៖** **ភីលីព ៤:១៣** *“ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

មនុស្សគ្រប់រូបត្រូវការជំនួយ និងអំណាចពីព្រះដើម្បីជួយឲ្យពួកគេយកឈ្នះការលំបាកក្នុងការរស់នៅលើផែនដីនេះ។ ព្រះយេស៊ូវផ្តល់អំណាចដល់អ្នកដើរតាមទ្រង់ និងជួយមិត្តសម្លាញ់របស់ពួកគេ! ហេតុអ្វីបានជាព្រះអនុញ្ញាត្តឱ្យអំពើទុច្ចរិតនៅតែបន្តកើតឡើង? យើងដឹងថាព្រះមានអំណាចបញ្ឈប់ការអាក្រក់ ហើយទ្រង់ជួយដល់ជនស្លូតត្រង់។ តើអ្នកទុកចិត្តទៅលើពេលវេលា និងរង់ចាំអំណាចរបស់ព្រះអង្គមកដល់ដែរឬទេ? វាជាការលំបាកសំរាប់គ្រីស្ទបរិស័ទជាច្រើន។ សូមចំណាយពេលអធិស្ឋាន៖ “អរគុណព្រះយេស៊ូវដែលបានជួយដល់កូនដោយអំណាចរបស់ទ្រង់។ សូមផ្តល់ភាពក្លាហានដល់កូននៅពេលដែលកូនរង់ចាំព្រះអង្គធ្វើការ”។

**ចំរៀង៖** ១. ផារ៉ោនតបថាទេ ២.ព្រះអង្គទ្រង់អស្ចារ្យ ៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** **«ល្បែងពត់ដៃ»**



ឲ្យកុមារចាប់ដៃគូទៅតាមអាយុឬមាឌរបស់ពួកគេហើយឲ្យពួកគេចាប់ផ្តើមពត់កម្លាំងដៃគ្នា អ្នកដែលមានកំលាំងខ្លាំងជាងគេគឺជាអ្នកឈ្នះ។ សូមរំលឹកកុមារថា ទោះបីជាគេមានកម្លាំងខ្លាំងជាងគេនៅក្នុងថ្នាក់ក៏ដោយ ក៏គេនៅតែមិនអាចខ្លាំងជាងអំណាចនៃព្រះបានដែរ។

**៤. ការណែនាំមេរៀន**

ព្រះទ្រង់មានអំណាចលើគ្រប់ទាំងអស់ នោះមានន័យថាទ្រង់ធំជាងបញ្ហារបស់យើង។ នៅពេលណាដែលយើងត្រូវការជំនួយនៅក្នុងជីវិតរបស់យើង នោះទ្រង់នឹងជួយយើងជានិច្ច។ ពេលខ្លះជីវិតយើងអាចនឹងជួបទុក្ខលំបាកដូចជាជនជាតិអ៊ីស្រាអែលដែរ ពួកគេបានធ្វើជាទាសកររស់រយៈជាង ៤០០ឆ្នាំ! ហើយពួកគេបានរង់ចាំយ៉ាងយូរដើម្បីឱ្យនរណាម្នាក់មកជួយពួកគេចេញពីការលំបាកនោះ។ ព្រះក៏បានចាត់ម៉ូសេឲ្យទៅជួយពួកគេ។ ដោយសារតែគ្មានអ្វីអាចនឹងប្រៀបផ្ទឹមស្មើនឹងអំណាចរបស់ព្រះបានឡើយ នោះយើងអាចទុកចិត្តព្រះអង្គ ដើម្បីឱ្យទ្រង់ធ្វើការគ្រប់យ៉ាងនៅក្នុងជីវិតយើងផងដែរ។ ព្រះអាចធ្វើឱ្យមានការល្អកើតចេញពីស្ថានភាពលំបាកបាន។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

តើនរណាមានអំណាចធំជាងគេនៅក្នុងក្រុមគ្រួសាររបស់ប្អូន? ក្នុងប្រទេសរបស់ប្អូន? ក្នុងភូមិរបស់ប្អូន? ក្នុងសាលារបស់ប្អូន? ផារ៉ោនដែលជាស្តេចរបស់អេស៊ីព្ទ គឺជាបុរសដែលមានអំណាចជាងគេនៅជំនាន់នោះ។ យ៉ាងណាមិញទាំងគាត់ និងឪពុកគាត់ពីដំណមុនៗបានទុកជនជាតិអ៊ីស្រាអែលធ្វើទាសកររអស់រយៈពេលជាង៤០០ឆ្នាំ។ វាត្រូវប្រើពេលវេលាយូរដើម្បីធ្វើឱ្យមនុស្សទាំងនោះស្តាប់បង្គាប់ និងត្រូវឃ្លាំមើលពួកគេមិនឲ្យរត់គេចបាន ។ ប៉ុន្តែព្រះចង់ជួយរំដោះជនជាតិអ៊ីស្រាអែល។ យើងដឹងថាព្រះទ្រង់មានអំណាច, តើប្អូនគិតថារវាងផារ៉ោននិងព្រះអ្នកណាមានអំណាចជាង? រឿងនៅព្រះគម្ពីរនៅថ្ងៃនេះប្រៀបដូចជាការប្រកួតប្រជែងរវាងផារ៉ោននិងព្រះអញ្ជើង។ ព្រះបានធ្វើការអស្ចារ្យដើម្បីធ្វើយ៉ាងណាឲ្យផារ៉ោនដោះលែងជនជាតិអ៊ីស្រាអែលឲ្យមានសេរីភាព។ ជំនួសឲ្យការជឿលើព្រះ ផារ៉ោនបានព្យាយាមផ្ទាញ់ផ្ទាលអំណាចរបស់ព្រះទៅវិញ។ ផារ៉ោនបានបញ្ជាឱ្យគ្រូអាបធ្មប់របស់ខ្លួនធ្វើត្រាប់តាមការអស្ចារ្យរបស់ព្រះផងដែរ។ ប្រហែលជាមានប្អូនខ្លះមិនបានដឹងទេថាពួកគ្រូអាបធ្មប់ទាំងនោះអាចធ្វើបានមែន! សូមចងចាំថា ផារ៉ោនគឺជាបុរសខ្លាំងពូកែម្នាក់មកពីគ្រួសារដែលមានអំណាច។

ចែកកុមារជាពីរក្រុម ក្រុមមួយនឹងតំណាងឱ្យផារ៉ោន ហើយក្រុមមួយទៀតតំណាងឱ្យព្រះ។ នៅពេលណាដែលខាងផារ៉ោនឬ ព្រះទទួលបានជោគជ័យក្នុងការបង្ហាញការអស្ចារ្យ កុមារម្នាក់ត្រូវក្រោកឈរឡើង។ នៅចុងបញ្ចប់នៃសាច់រឿង ក្រុមដែលមានកុមារឈរច្រើនជាងគេគឺជាក្រុមដែលឈ្នះ! ត្រៀមខ្លួនហើយឬនៅ?

- ម៉ូសេបានបោះដំបងទៅលើដីហើយវាបានក្លាយទៅជាសត្វពស់! ឲ្យកុមារម្នាក់ក្នុងក្រុមដែលតំណាងឱ្យ “ព្រះ” ងើបឈរឡើង
- គ្រូអាបធ្មប់របស់ផារ៉ោនបានធ្វើឲ្យដំបងឈើក្លាយទៅជាសត្វពស់។ ឲ្យកុមារម្នាក់ក្នុងក្រុមដែលតំណាងឱ្យ “ផារ៉ោន” ងើបឈរឡើង
- សត្វពស់របស់ម៉ូសេលេបសត្វពស់របស់ផារ៉ោន។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ “ព្រះ”ងើបឈរឡើង
- ព្រះបានធ្វើឲ្យទឹកក្លាយទៅជាឈាម។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ “ព្រះ” ងើបឈរឡើង
- គ្រូអាបធ្មប់របស់ផារ៉ោនបានធ្វើឲ្យទឹកក្លាយទៅជាឈាម។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ “ផារ៉ោន” ងើប-ឈរឡើង
- ព្រះបានធ្វើឱ្យកង្កែបរាប់ពាន់ក្បាលលោតចុះលោតឡើងគ្រប់ទីកន្លែង។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ “ព្រះ” ងើបឈរឡើង
- គ្រូអាបធ្មប់បានធ្វើឱ្យមានកង្កែបជាច្រើនចេញមក។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ “ផារ៉ោន” ងើបឈរឡើង
- ព្រះបានប្រែក្លាយធូលីដីទៅជាសត្វល្អិត។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ “ព្រះ” ងើបឈរឡើង
- គ្រូអាបធ្មប់បានព្យាយាមប្រែក្លាយធូលីដីទៅជាសត្វល្អិតប៉ុន្តែពួកគេមិនអាចធ្វើបានទេ។ គ្រូអាបធ្មប់នោះបានប្រាប់ផារ៉ោនឱ្យបោះបង់និងឲ្យគាត់ជឿលើព្រះទៅ។ ឲ្យកុមារម្នាក់នៅក្នុងក្រុមរបស់ “ផារ៉ោន” អង្គុយចុះ។

- ព្រះបានធ្វើឱ្យរុយរាប់ពាន់ក្បាលលេចឡើងនៅគ្រប់ទីកន្លែង។ សត្វរុយទាំងអស់នោះរំខានផារ៉ោន និងជនជាតិអេស៊ីព្ទយ៉ាងខ្លាំងប៉ុន្តែវាមិនរំខានដល់រាស្ត្ររបស់ព្រះទេ។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង។
- ព្រះបានបង្កើតភាពងងឹតអស់រយៈពេលបីថ្ងៃ ដោយគ្មានព្រះអាទិត្យព្រះច័ន្ទឬផ្កាយឡើយ។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង។
- គ្រូអាបធ្មប់ទាំងនោះឈប់ព្យាយាមធ្វើតាមផារ៉ោនបញ្ជាព្រោះពួកគេមើលអ្វីមិនឃើញទៀតទេ! ពួកគេបានបោះបង់ការចង់ធ្វើខ្លួនឲ្យដូចជាព្រះហើយ។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ផារ៉ោន" អង្គុយចុះ។

តើក្រុមណាជាអ្នកឈ្នះ? ចាស៎/បាទ ក្រុមតំណាងឱ្យព្រះជាអ្នកឈ្នះ! ព្រះអង្គឈ្នះព្រោះគ្មានអ្វីដែលមានអំណាចធំជាងព្រះនោះទេ។ ព្រះបានរំដោះជនជាតិអ៊ីស្រាអែលពីផារ៉ោន!

**៦. សំនួរពិភាក្សា**

១. តើជនជាតិអ៊ីស្រាអែលជាប់ជាទាសករនៅប្រទេសអេស៊ីព្ទអស់រយៈពេលប៉ុន្មានឆ្នាំ? *៤០០ឆ្នាំ*

២. តើព្រះចង់ធ្វើអ្វីដើម្បីជនជាតិអ៊ីស្រាអែល? *ទ្រង់ចង់ដោះលែងពួកគេពីភាពជាទាសករ*

៣. រវាងព្រះ និងផារ៉ោន តើនរណាមានអំណាចធំជាង? *ព្រះ*

៤. តើប្អូនគួរធ្វើដូចម្តេចនៅពេលប្អូនត្រូវការជំនួយនៅក្នុងជីវិត?

*ទូលសូមព្រះ ព្រោះគ្មានអ្វីដែលមាន អំណាចជាងព្រះទេ*

**៧. ខគម្ពីរចងចាំ** **ភីលីព ៤:១៣**

**៨. ហត្ថកម្ម** «ព្រះជាទីមួយ»



កាត់រូបប្រអប់ដៃពីរសំរាប់កុមារម្នាក់ៗ ហើយយកការមកបិតគែមៗនៃប្រអប់ដៃ ទាំង២នោះឲ្យជាប់គ្នា(ធ្វើយ៉ាណាអាចដាក់ប្រអប់ដៃម្ខាងចូលបាន)។ សូមសរសេរពាក្យ ថា "ព្រះជាទីមួយ" នៅលើដៃនោះ។ យករូបដៃនោះមកស៊កក្នុងដៃរបស់កុមារ ហើយឲ្យកុមារទាំងអស់គ្នា និយាយថា "ព្រះជាទីមួយ" ។




**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

